ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និងឈ្មោះសំណុំរឿង : ១៧/០៨-វីនណើ ណើតធីង**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៨**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

## (ធ្វើឡើងស្របតាមមាត្រា៣១៧នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាលៈ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **ម៉ារ សំបូរណា**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **សុខ ម៉ាធឿង**

**ភាគីនៃវិវាទ**

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន វីនណើ ណើតធីង**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២១ ភូមិលេខ ៤ ឃុំ ស្វាយរលំ ស្រុក ស្អាង ខេត្ត កណ្តាល

ទូរស័ព្ទ: ០១៦ ៩៥១ ១៨៨ ទូរសារលេខ : គ្មាន

តំណាងភាគីនិយោជក :

១- លោក ជា លីឆាយ រដ្ឋបាលក្រុមហ៊ុន

២-លោក សេង ចំរើន ជំនួយការរដ្ឋបាល

៣- លោក ឡុង ហ៊ាង តំណាងសមាគមកាត់ដេរ



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

២- ភាគីកម្មករនិយោជិត

ឈ្មោះ : **សម្ព័ន្ធសហជីព_សហជីព ស៊ីខៅខ្ញូ**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២១ ភូមិលេខ ៤ ឃុំ ស្វាយរលំ ស្រុក ស្អាង ខេត្ត កណ្តាល

ទូរស័ព្ទ : ០១២ ៩៨៨ ៦២៣ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត :

១-លោកស្រី មាស វណ្ណី មន្ត្រីសម្ព័ន្ធសហជីពស៊ីខៅខ្ញូ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សូមឱ្យក្រុមហ៊ុនអនុវត្តកិច្ចព្រមព្រៀងក្នុងការផ្តល់ប្រាក់ចំនួន ៥០០ ដុល្លារអាមេរិក ដល់កម្មករណា ដែលលាឈប់ពីការងារដែលក្រុមហ៊ុនធ្លាប់បានអនុវត្តកន្លងមក ។ ភាគីក្រុមហ៊ុនមិនឯកភាព គឺអនុវត្តតាមច្បាប់ការងារ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូក ទី ១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ០១២/០៨ ក.ប/កណ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៨ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៨ ។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៨ (វេលាម៉ោង ១៤:៣០ ដល់ម៉ោង ១៦:០០ នាទី )។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ២០០៨ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានធ្វើការផ្សះផ្សាវិវាទការងាររួមចំនួន០២ចំណុច ដោយទទួលលទ្ធផលមិនសះជានឹងគ្នាចំនួន០១ចំណុចលើការទាមទារទាំងអស់ចំនួន០២ចំណុច ដែលត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៨។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា និងកម្មករនិយោជិតពាក់ព័ន្ធមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន០១ ចំណុចនេះ នាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៨ វេលាម៉ោង ១៤:៣០ រសៀល។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាបន្ត ប៉ុន្តែភាគីទាំងពីរមិនបានសះជានឹងគ្នាលើចំណុចបញ្ហានេះឡើយ។ ហេតុដូច្នេះ នៅក្នុងសេចក្តីបង្គាប់នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើចំណុចមិនសះជាចំនួន០១ចំណុច ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម :

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១-សារណាសង្ខេបស្តីពីសកម្មភាពក្រុមហ៊ុន វីនណឺ ណីតធីង ហ្វាក់តូរី ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ។

២-កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន វីនណឺ ណីតធីង ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ ២០០៧ ។

៣-វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងក្រុមហ៊ុនលេខ ១០៥០ ពណ.ពកប.កន របស់ក្រុមហ៊ុន វីនណឺ ណីតធីង ចុះថ្ងៃទី ខែមេសា ឆ្នាំ១៩៩៧ ។

៤-បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន វីនណឺ ណីតធីងលេខ ០៤២ សកបយ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ។

៥-អនុស្សរណៈ និង លក្ខន្តិកៈក្រុមហ៊ុនវីនណឺ ណីតធីង ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០០ ។

៦-លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុនវីនណឺ ណីតធីង ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៨ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :

១-កំណត់ហេតុចរចារគ្នារវាងក្រុមហ៊ុន និង សហពន្ធ័សហជីពយុវជនខ្មែរ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៧ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១-របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន វីនណឺ ណីតធីង លេខ ០១២ កប/កណ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៨។

២-កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ក្រុមហ៊ុន វីនណឺ ណីតធីង ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៨។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១-លិខិតអញ្ជើញភាគីក្រុមហ៊ុនចូលរួមសវនាការ លេខ ០៩៥ កប/អក/វក/លកអ. ចុះថ្ងៃទី០៤ ខែ កុម្ភៈ ឆ្នាំ២០០៨។

២-លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៩៦ កប/អក/វក/លកអ. ចុះ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៨។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យឯកសារផ្សេងៗដែលត្រូវបានដាក់ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល
- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជកក្រោយពីបាន ពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

**ចំណុចទី ១: សូមឱ្យក្រុមហ៊ុនអនុវត្តកិច្ចព្រមព្រៀងក្នុងការផ្តល់ប្រាក់ចំនួន ៥០០ ដុល្លារអាមេរិក ដល់កម្មករណា ដែលលាឈប់ពីការងារ ដែលក្រុមហ៊ុនធ្លាប់បានអនុវត្តកន្លងមក ។**

- សហជីព ស៊ីខៅខ្វ មូលដ្ឋានមិនបានមកចូលរួមក្នុងសវនាការឡើយ មន្ត្រីសម្ព័ន្ធសហជីពបានលើកឡើងថា ដោយសារសហជីពមូលដ្ឋានបានសុំច្បាប់ទៅស្រុក។ នៅក្នុងសវនាការមានតែមន្ត្រីសម្ព័ន្ធសហជីពស៊ីខាខ្វ ដែលបាន ចូលរួមសវនាការតំណាងអោយភាគីកម្មករ ។ សហជីពស៊ីខាខ្វមូលដ្ឋានមានសមាជិកចំនួនប្រមាណ ៧០០ នាក់ ហើយដែលចំនួនកម្មករសរុប ៤០៦៧នាក់ ។ សហជីពស៊ីខាខ្វមិនមានភាពជាតំណាងនៅក្នុងក្រុមហ៊ុនឡើយ។

- នៅក្នុងក្រុមហ៊ុនមានសហជីពចំនួន ៥ គឺ សហជីពសេរីកម្មករ, សហជីពយុវជនខ្មែរ, សហជីពកម្មករនិយោជិត, សហជីពពលករខ្មែរ និង សហជីពស៊ីខៅខ្វ ។

- មានកំណត់ហេតុផ្សះផ្សាពីរទាក់ទងទៅនឹងកិច្ចព្រមព្រៀង (ការសះជាគ្នា) ស្តីពីការផ្តល់ប្រាក់ចំនួន ៥០០ ដុល្លារអាមេរិក ដល់កម្មករនិយោជិតភេទប្រុសដែលធ្វើការបានប្រាំឆ្នាំ ហើយមានបំណងលាឈប់ពីក្រុមហ៊ុន ដែលបានធ្វើឡើងរវាងក្រុមហ៊ុន និងសហព័ន្ធសហជីពយុវជនខ្មែរ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៧ ដោយមួយធ្វើចប់នៅវេលា ម៉ោង ១១ :៣០ នៅក្រុមហ៊ុន ដោយមានចុះហត្ថលេខាទាំងពីរភាគី ។មានកំណត់ហេតុផ្សះផ្សាមួយទៀតធ្វើចប់នៅវេលា ម៉ោង ១២:០០ នៅអធិការការងារ ដោយមានចុះហត្ថលេខាតែភាគី ក្រុមហ៊ុន តែភាគីកម្មករបានដើរចេញពីអង្គប្រជុំ ។

- ក្រុមហ៊ុនបញ្ជាក់ថា មូលហេតុនៃការធ្វើកិច្ចព្រមព្រៀងនោះគឺ ដោយសារក្រុមហ៊ុនចង់បញ្ឈប់នូវកូដកម្ម ប៉ុន្តែ សំរាប់កម្មករមួយចំនួនតូចដែលមានបំណងចង់លាឈប់ពីការងារប៉ុណ្ណោះ ។ តែកិច្ចព្រមព្រៀងនៅកាលនោះមិនបានយកមកអនុវត្តទេ ដោយសារតែកម្មករមិនបានលាឈប់ធ្វើការ ។ នៅពេលនេះមិនមានកម្មករណាមួយលាឈប់នៅឡើយទេ ។

- មន្ត្រីសម្ព័ន្ធសហជីពបានអះអាងថា មានកម្មករមួយចំនួនមានបំណងចង់លាឈប់ ហើយបានសាកសួរក្រុមហ៊ុនថា ពួកគេអាចទទួលបានប្រាក់ចំនួន ៥០០ ដុល្លារអាមេរិក ដូចមានចែងក្នុងកំណត់ហេតុនាពេលនោះដែរឬទេ? តែក្រុមហ៊ុនបាន បញ្ជាក់ថា កិច្ចព្រមព្រៀង ដែលក្រុមហ៊ុនបានធ្វើក្នុងកំណត់ហេតុខាងលើនេះ ត្រូវបានក្រុមហ៊ុន បដិសេធចោលយូរមកហើយ ព្រោះភាគីកម្មករនៃកិច្ចព្រមព្រៀងក្នុងកំណត់ហេតុនោះ ក៏មិនបានគោរពតាមខ្លឹមសារនៃការព្រមព្រៀងនាពេលនោះ ហេតុនេះក្រុមហ៊ុនបានបដិសេធចោលកិច្ចព្រមព្រៀងនោះហើយ ។ ហេតុនេះ ក្រុមហ៊ុនមិនផ្តល់ឱ្យទឹកប្រាក់ចំនួន ៥០០ដុល្លារអាមេរិក ចំពោះកម្មករណាដែលលាឈប់នោះឡើយ គឺត្រូវអនុវត្ត តាមច្បាប់ស្តីពីការងារ ។

- មន្ត្រីសម្ព័ន្ធសហជីពបានអះអាងថា បច្ចុប្បន្នមិនមានកម្មករណាម្នាក់បានលាលែង និងបានធ្វើការទាមទារចំនួនទឹកប្រាក់ ៥០០ ដុល្លារអាមេរិក នេះឡើយ ។ នេះគ្រាន់តែជាការទាមទារសំរាប់ជូនដល់កម្មករទាំងឡាយណាដែលមានបំណងលាឈប់នាពេលអានាគត ។

## ហេតុផលនៃសេចក្តីសំរេច

**<u>ចំណុចទី ១: សូមឱ្យក្រុមហ៊ុនអនុវត្តកិច្ចព្រមព្រៀងក្នុងការផ្តល់ប្រាក់ចំនួន ៥០០ ដុល្លារអាមេរិក ដល់កម្មករណាដែលលាឈប់ពីការងារ ដែលក្រុមហ៊ុនធ្លាប់បានអនុវត្តកន្លងមក ។</u>**

ដើម្បីធ្វើការពិចារណាទៅលើការទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវការពិចារណាទៅលើភស្តុតាងជាក់លាក់ទាក់ទងទៅនឹងកម្មករនិយោជិតដែលធ្វើការទាមទារ ដូចជាឈ្មោះកម្មករនិយោជិតដែលធ្វើការទាមទារ ប្រភេទនៃកិច្ចសន្យា រយៈពេលធ្វើការរបស់កម្មករនិយោជិតទាំងនោះនៅក្នុងក្រុមហ៊ុន កម្មករទាំងនោះស្រី រឺប្រុស ។ល។ នៅក្នុងសំណុំរឿងនេះមន្ត្រីសម្ព័ន្ធសហជីពមិនបានផ្តល់ភស្តុតាង និងព័ត៌មានជាក់លាក់ទាក់ទងទៅនឹងកម្មករណាម្នាក់ ដែលត្រូវបានលាឈប់ពីការងារ ហើយទាមទារប្រាក់ចំនួន ៥០០ ដុល្លារអាមេរិកនេះឡើយ ។ មន្ត្រី



THE ARBITRATION COUNCIL

សម្ព័ន្ធសហជីព គ្រាន់តែធ្វើការទាមទារសំរាប់កម្មករនិយោជិត ដែលអាចនឹងធ្វើការលាឈប់នាពេលអនាគតដើម្បីទទួលបាននូវប្រាក់ចំនួន ៥០០ ដុល្លារអាមេរិកនេះ ។ មានន័យថា វិវាទទាក់ទងនឹងការទាមទារចំនួនទឹកប្រាក់ ៥០០ ដុល្លារអាមេរិកនេះមិនទាន់កើតមាននៅឡើយទេ រវាងនិយោជក និងកម្មករនិយោជិត ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ជាវិវាទនៅពេលអនាគត ។

ចំពោះវិវាទនៅពេលអនាគត ក្រុមប្រឹក្សាអាជ្ញាកណ្តាលសំរេចមិនពិចារណាលើការទាមទារនេះឡើយ ដោយសារហេតុផលដូចខាងក្រោម:

ទាក់ទងនឹងការទាមទារឱ្យសំរាប់ពេលអនាគត នៅក្នុងសំណុំរឿងលេខ ១០/០៣-ហ្សាក់ស៊ីនតិក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា *"ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្កើតឡើងដើម្បីដោះស្រាយជម្លោះការងារ មិនមែនដើម្បីដោះស្រាយបញ្ហាមិនទាន់កើតឡើងនោះទេ ។"*

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពលើការបកស្រាយខាងលើនេះដែរព្រោះគ្មានអ្នកណាម្នាក់អាចទាយទុកមុនពីហេតុការណ៍ ដែលនឹងកើតឡើងនៅពេលអនាគតទេ ថាតើបញ្ហានោះអាចកើតមាន ឬអត់ ហើយកើតនៅទីណា នៅពេលណា ហើយកម្មករនិយោជិតណាខ្លះដែលត្រូវប៉ះពាល់ ។ ក្នុងករណីនេះក៏ដូចគ្នាដែរ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏មិនអាចទាយទុកមុនទេថា តើនឹងមានកម្មករប៉ុន្មាននាក់ ដែលនឹងលាឈប់ធ្វើការពីក្រុមហ៊ុនឡើយ ហើយជាពិសេសទៅទៀតនោះ នៅពេលដែលគ្មានអង្គហេតុពិតប្រាកដ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចកំណត់បានថា តើកម្មករដែលចង់លាឈប់នោះ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលត្រូវបានទទួលតំលៃខ្លួន ៥០០ ដុល្លាអាមេរិកស្របតាមកិច្ចព្រមព្រៀង រឺអត់ នៅពេលដែលគេលាឈប់ ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសំរេចមិនពិចារណាការទាមទាររបស់កម្មករនិយោជិតក្នុងចំណុចនេះឡើយ ។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសំរេចដូចតទៅនេះ :

## សម្រេច និង បង្គាប់

-បដិសេធពិចារណាការទាមទាររបស់សម្ព័ន្ធសហជីពស៊ីខៅខូ ដែលទាមទារឱ្យក្រុមហ៊ុនអនុវត្តកិច្ចព្រមព្រៀងក្នុងការផ្តល់ប្រាក់ចំនួន ៥០០ ដុល្លារ ដល់កម្មករណា ដែលលាឈប់ពីការងារ ។

**ប្រភេទនៃសេចក្ដីបង្គាប់ : សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្ដីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន១០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ ។*

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ម៉ៅ សំបូរណា**

ហត្ថលេខា: ---------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អន ណាន**

ហត្ថលេខា: ---------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល :

ឈ្មោះ : **សុខ ម៉ាឡឿង**

ហត្ថលេខា: ---------------------------------